ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ២៤០ ប្រក.កសក

# ប្រកាស
## ស្ដីពី
## ការធ្វើចំណាត់ថ្នាក់សត្វព្រៃបន្ថែម ក្នុងឧបសម្ព័ន្ធនៃប្រកាសលេខ០២០ប្រក.កសក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០០៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០២ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការអនុម័តយល់ព្រមលើអនុសញ្ញាស្ដីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្ដីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**ប្រការ២._**

ក្រៅពីការធ្វើចំណាត់ថ្នាក់សត្វព្រៃបន្ថែមក្នុងឧបសម្ព័ន្ធ ខ្លឹមសារទាំងឡាយនៃប្រកាសលេខ០២០ ប្រក.កសក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០០៧ ត្រូវបានរក្សាទុកដដែល។

**ប្រការ៣._**

អគ្គលេខាធិការ អគ្គាធិការ ប្រធានរដ្ឋបាលព្រៃឈើ ប្រធានរដ្ឋបាលជលផល អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ ប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលពាក់ព័ន្ធ និងប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ [illegible] ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែសីហា ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងបរិស្ថាន
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី-ខេត្ត
- ដូចប្រការ៣
- ឯកសារ កាលប្បវត្តិ

- បានឃើញអនុក្រឹត្យលេខ៥៣ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៦ ស្តីពីការធ្វើពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វនិងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់
- បានឃើញប្រកាសលេខ០២០ ប្រក.កសក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០០៧ ស្តីពីចំណាត់ថ្នាក់និងបញ្ជីឈ្មោះសត្វព្រៃ
- យោងតាមសំណើរបស់ប្រធានរដ្ឋបាលព្រៃឈើ

**សម្រេច**

ប្រការ១._

ត្រូវបានធ្វើចំណាត់ថ្នាក់សត្វព្រៃបន្ថែមចំនួន១២ប្រភេទ រួមមាន៖ ដំរីអាហ្វ្រិក ពពួកសត្វរមាសចំនួន៤ប្រភេទ និងពពួកសត្វពង្រូល៧ប្រភេទ ព្រមទាំងសំណាករបស់ប្រភេទសត្វទាំងនេះ ក្នុងឧបសម្ព័ន្ធនៃប្រកាសលេខ០២០ ប្រក.សេក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០០៧ ស្តីពីចំណាត់ថ្នាក់និងបញ្ជីឈ្មោះសត្វព្រៃ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូចខាងក្រោម៖

## ក្រុមប្រភេទជិតផុតពូជ

**ក - ថនិកសត្វ**

| ល.រ | ឈ្មោះខ្មែរ | ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះអង់គ្លេស | ឧបសម្ព័ន្ធ CITES |
|---|---|---|---|---|
| ១ | ដំរីអាហ្វ្រិក | *Loxodonta africana* | African elephant | I |
| ១ | រមាសស | *Ceratotherium simum* | White Rhinoceros | I |
| ៣ | រមាសខ្មៅ | *Diceros bicornis* | Black Rhinoceros | I |
| ៤ | រមាសឥណ្ឌាឬរមាសកុយ១ | *Rhinoceros unicornis* | Indian Rhinoceros | I |
| ៥ | រមាសស៊ុមាត្រា | *Dicerorhinus sumatrensis* | Sumatran Rhinoceros | I |

## ក្រុមប្រភេទមានលោយភាព្រ

**ក - ថនិកសត្វ**

| ល.រ | ឈ្មោះខ្មែរ | ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះអង់គ្លេស | ឧបសម្ព័ន្ធ CITES |
|---|---|---|---|---|
| ១ | ពង្រូលឥណ្ឌា | *Manis crassicaudata* | Indian pangolin | I |
| ២ | ពង្រូលហ្វីលីពីន | *Manis culionensis* | Philippine pangolin | I |
| ៣ | ពង្រូលចិន | *Manis pentadactyla* | Chinese pangolin | I |
| ៤ | ពង្រូលយក្ស | *Smutsia gigantea* | Giant Ground pangolin | I |
| ៥ | ពង្រូលតូច | *Smutsia temmincki* | Temminck's Ground pangolin | I |
| ៦ | ពង្រូលពោះខ្មៅ | *Phataginus tetradactyla* | Black-bellied pangolin | I |
| ៧ | ពង្រូលពោះស | *Phataginus tricuspis* | White-bellied pangolin | I |